00778054

E163/corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 09-Feb-2012, 10:07
CMS/CFO: Kauv Keoratanak

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| **កែលើឯកសារលេខ៖** | **ERN(s):** | **កាលបរិច្ឆេទ៖** | **ប្រភេទកំណែ៖** |
|---|---|---|---|
| E163 | ERN 00773848-00773867 | ០៨-០២-២០១២ | ☐ កែលើឯកសារដើម<br>☒ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| **មូលហេតុនៃការកែតម្រូវ៖** |
|---|
| កែតម្រូវពាក្យសំណុំរឿង០០១ ទៅជា សំណុំរឿង ០០២ ត្រង់ ERN 00773850. |

| **សេចក្តីលម្អិតនៃការកែតម្រូវ៖** |
|---|
| |

ស្នើដោយ៖ផាន់ សុជា ក្រឡាបញ្ជីការិយាល័យសហព្រះរាជអាជ្ញា ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

00778055

E163/corr-1



## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១- នៅក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ របស់ខ្លួន ដែលបំបែកទៅជាការជំនុំជម្រះជាច្រើនខុសៗគ្នា អង្គជំនុំជម្រះសាលាដំបូង[1] ("អង្គជំនុំជម្រះ") បានបញ្ជាក់ថា៖

Deleted: ១

> ... *ក្នុងពេលណាមួយអាចសម្រេចបញ្ចូលនៅក្នុងសវនាការដំបូងនូវចំណែកនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ដោយគិតពីសិទ្ធិរបស់មេធាវីការពារក្តីដែលនឹងត្រូវផ្តល់នូវឱកាស ដើម្បីត្រៀមរៀបចំកិច្ចការពារឱ្យមានប្រសិទ្ធភាព ហើយភាគីទាំងអស់នឹងត្រូវជូនដំណឹងទាន់ពេលវេលា*[2]។

២- ដោយបានពិចារណា និងបដិសេធសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ ចំពោះការបំបែកកិច្ចដំណើរការនីតិវិធី[3] អង្គជំនុំជម្រះបានធ្វើការសង្កេតថា៖

> ... *មិនបានច្រានចោលលទ្ធភាពនៃការបញ្ចូលបន្ថែមបទចោទទៅក្នុងសវនាការជំនុំជម្រះលើកទីមួយក្នុងសំណុំរឿង ០០២ ទេ បើសិនជាកាលៈទេសៈអនុញ្ញាត។ អង្គជំនុំជម្រះកត់សម្គាល់នូវការចង្អុលបង្ហាញរបស់សហព្រះរាជអាជ្ញានៅក្នុងសំណើសុំរបស់ខ្លួនអំពីបញ្ហាបន្ថែមដែលអាចមានសម្រាប់ដាក់បញ្ចូលនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូង ហើយអង្គជំនុំជម្រះត្រូវបានណែនាំដោយការយល់ឃើញរបស់សហព្រះរាជអាជ្ញាថាជាការចោទប្រកាន់ជាអាទិភាព សម្រាប់ធ្វើការពិចារណាក្នុងអំឡុងដំណាក់កាលនៃការជំនុំជម្រះក្រោយៗទៀត...*[4]។

៣- នៅក្នុងកិច្ចប្រជុំគ្រប់គ្រងសវនាការក្រៅផ្លូវការ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកកិច្ចការច្បាប់បានបញ្ជាក់ក្នុងនាមអង្គជំនុំជម្រះថា អង្គជំនុំជម្រះនៅតែបើកចំហរ នៅក្នុងការពង្រីក

---

[1] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង", ២២ កញ្ញា ២០១១ ("ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី")។

[2] **E124** *ដដែលដូចខាងលើ* ត្រង់កថាខ័ណ្ឌទី ៦។

[3] **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ១៨ តុលា ២០១១ ត្រង់កថាខ័ណ្ឌទី ១២ ។

[4] **E124/7** *ដដែលដូចខាងលើ* ត្រង់កថាខ័ណ្ឌទី ១២។